ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ. ៩៦៧.....សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការកំណត់មូលដ្ឋានគិតពន្ធប្រថាប់ត្រា

## ចំពោះការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- ព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- ព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥
- ក្រឹត្យលេខ ២១ ក្រ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតពន្ធប្រថាប់ត្រា
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩១ ស្តីពីការប្រមូលពន្ធប្រថាប់ត្រា
- បានឃើញប្រកាសលេខ ៧៣៥ សហវ.ប្រក.អពដ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៣ ស្តីពីការប្រមូលពន្ធប្រថាប់ត្រា
- យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.- គោលដៅ**

ប្រកាសនេះមានគោលដៅកំណត់មូលដ្ឋានគិតពន្ធប្រថាប់ត្រា ដែលត្រូវអនុវត្តចំពោះការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ។

**ប្រការ២.- គោលបំណង**

ប្រកាសនេះមានគោលបំណងធានាសង្គតិភាពនិងប្រសិទ្ធភាពនៃការប្រមូលពន្ធប្រថាប់ត្រាចំពោះការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ។

**ប្រការ៣.- វិសាលភាព**

ប្រកាសនេះមានវិសាលភាពអនុវត្ត ចំពោះការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ ដែលជាសំណង់ ឬ/និងដី ស្ថិតក្នុងភូមិសាស្ត្ររដ្ឋបាលរាជធានីនិងខេត្ត នៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤.- និយមន័យនៃពាក្យស័ព្ទក្នុងឧបសម្ព័ន្ធ**

សម្រាប់ឧបសម្ព័ន្ធនៃប្រកាសនេះ វាក្យស័ព្ទខាងក្រោម មានន័យដូចតទៅ÷

- "តំបន់" សំដៅដល់បណ្តុំនៃខណ្ឌពីរ ឬច្រើន នៃរាជធានីភ្នំពេញ ដែលរួមមានតំបន់ I និង តំបន់ II នៃរាជធានីភ្នំពេញ ដូចមានចែងក្នុងឧបសម្ព័ន្ធ។
- "ផ្លូវមេ" សំដៅដល់ផ្លូវសំខាន់ៗទាំងឡាយ ដែលមានឈ្មោះ ឬលេខ ដូចមានចែងក្នុងឧបសម្ព័ន្ធ។
- "ផ្លូវរណប" សំដៅដល់ផ្លូវទាំងឡាយដែលនៅស្របនឹងផ្លូវមេ និងភ្ជាប់ផ្លូវមេណាមួយ។
- "ច្រកផ្លូវ" សំដៅដល់ផ្លូវទាំងឡាយដែលមានលក្ខណៈទ័លឬតូចចង្អៀតស្ថិតនៅចន្លោះផ្លូវមេ ឬចន្លោះផ្លូវរណប។
- "ផ្លូវឃុំឬផ្លូវសង្កាត់" សំដៅដល់ផ្លូវទាំងឡាយដែលតភ្ជាប់ពីផ្លូវមេក្នុងតំបន់ II នៃរាជធានីភ្នំពេញ ឬផ្លូវទាំងឡាយដែលភ្ជាប់ពីផ្លូវមេក្នុងក្រុង ឬស្រុក នៃបណ្តាខេត្តនានា។
- "ផ្លូវភូមិ" សំដៅដល់ផ្លូវទាំងឡាយដែលតភ្ជាប់ពីផ្លូវឃុំ ឬផ្លូវសង្កាត់ ឬបណ្តាញផ្លូវពីភូមិមួយទៅភូមិមួយ ក្នុងតំបន់ II នៃរាជធានីភ្នំពេញ ឬក្នុងក្រុង ឬស្រុក នៃបណ្តាខេត្តនានា។

**ប្រការ៥.- មូលដ្ឋានគិតពន្ធប្រថាប់ត្រា**

ដោយអនុលោមតាមច្បាប់ជាធរមាន ពន្ធប្រថាប់ត្រា ត្រូវបានកំណត់តាមអត្រា ៤% នៃតម្លៃអចលនទ្រព្យ ដែលជាកម្មវត្ថុនៃការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់។

មូលដ្ឋានគិតពន្ធប្រថាប់ត្រា ត្រូវបានកំណត់តាមលំដាប់អាទិភាពដូចខាងក្រោម÷

១- តម្លៃអចលនទ្រព្យដែលត្រូវបានកំណត់ ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ

២- តម្លៃអចលនទ្រព្យ ដែលត្រូវបានកំណត់ ក្នុងកិច្ចសន្យាផ្ទេរសិទ្ធិកម្មសិទ្ធិឬសិទ្ធិកាន់កាប់ ឬលិខិតគតិយុត្ត ពាក់ព័ន្ធផ្សេងទៀត ក្នុងករណីដែលមានតម្លៃស្មើ ឬខ្ពស់ជាងតម្លៃ ដែលមានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៦._ អវសានប្បញ្ញត្តិ**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧._ ការអនុវត្តប្រកាស**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយក នៃអគ្គនាយកដ្ឋាន អគ្គាធិការ នៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

បណ្ឌិត. **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ